# ពហិការរបស់ដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមនៅពេលដែលការធ្វើសក្ខីកម្មរបស់សាក្សីអត្តចរិត ស្របពេលជាមួយអ្នកជំនាញផ្តល់ការវាយតម្លៃផ្នែកចិត្តសាស្ត្ររបស់ ឌុច

*ដោយលោក ម៉ៃខល សាលីបា*

*ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត និង វ៉ាន់ថាន់ ពៅដារ៉ា*

ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលរួមជាប់លាប់ក្នុងសវនាការជំនុំជម្រះសេចក្តីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ (ហៅ ឌុច) មិនមានវត្តមានយ៉ាងច្បាស់ក្រឡែតនៅក្នុងបន្ទប់សវនាការទេនាព្រឹកនេះ ។ នៅក្នុងសន្និសិទកាសែតដែលធ្វើឡើងនៅឯច្រកចូលរបស់តុលាការប៉ុន្មាននាទីមុននេះ លោកអ៊ំ ជុំ ម៉ី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងជាអ្នករស់រានមានជីវិតពីគុកទួលស្លែង (មន្ទីរស-២១) បានពន្យល់ប្រាប់ថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨នាក់ កំពុងតែធ្វើពហិការមិនចូលរួមក្នុងដំណើរនីតិវិធីរបស់តុលាការនៅក្នុងសប្តាហ៍នេះ ដើម្បីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលរារាំងមេធាវីរបស់ខ្លួនមិនឲ្យចោទសួរជាសំណួរទៅកាន់សាក្សីអត្តចរិត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានសម្តែងការស្រងាកក្នុងចិត្តចំពោះអ្វីដែលខ្លួនយល់ឃើញថាជាការដាក់កម្រិតលើសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន និងការបំបិទមាត់មេធាវីរបស់ខ្លួនមិនឲ្យនិយាយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ការពិត និងយុត្តិធម៌មិនអាចសម្រេចបានទេ ប្រសិនបើខ្លួនមិនត្រូវបានផ្តល់ឱកាសដើម្បីចោទសួរទៅកាន់សាក្សីអត្តចរិតដើម្បីជួយឲ្យខ្លួនបានយល់ពីហេតុផល និងគោលបំណងរបស់ជនជាប់ចោទ ។

ដើមបណ្តឹងរដ្ឋប្បវេណី មានគម្រោងចេញជាលិខិតចំហរមួយជូនដល់អង្គជំនុំជម្រះសាលាដំបូងដើម្បីស្នើសុំការផ្លាស់ប្តូរសេចក្តីសម្រេចរបស់ខ្លួន ។ ពុំទាន់មានការណ៍ច្បាស់លាស់នៅឡើយទេដែលថា តើមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងប្តឹងឧទ្ធរណ៍ជាផ្លូវការប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឬយ៉ាងណានោះ ។(ខណៈពេលដែលប្រភេទនៃសេចក្តីសម្រេចមួយចំនួនត្រូវបានចាត់ទុកថា ជាបុរេនិច្ច័យសម្រាប់ភាគីគឺត្រូវប្តឹងឧទ្ធរណ៍ភ្លាមៗ ដែលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចពិសេសនេះ គឺត្រូវធ្វើឡើងក្នុងពេលស្របគ្នានឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមសម្រេចសេចក្តី) ។

ជាមួយគ្នានេះ ដើមបណ្តឹងរដ្ឋប្បវេណីបានសម្តែងការតវ៉ាជាច្រើនលើកចំពោះការប្រព្រឹត្តមិនស្មើភាពគ្នា រវាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីជនត្រូវចោទ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ឃើញថា ឌុច ត្រូវបានផ្គត់ផ្គង់របបអាហារគ្រប់គ្រាន់ និងផ្តល់កន្លែងស្នាក់នៅសមរម្យដោយតុលាការ ចំណែកឯ ដើមបណ្តឹងរដ្ឋប្បវេណីវិញ មិនត្រូវបានផ្តល់ជាជំនួយអ្វីឡើយ ហើយត្រូវតស៊ូនឹងស្ថានភាពរស់នៅ ប្រចាំថ្ងៃរបស់ខ្លួនថែមទៀតផង ។ ស្រដៀងគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា មេធាវីការពារក្តីទទួលបានប្រាក់បៀវត្សរ៍ដ៏ច្រើនពីតុលាការ រីឯមេធាវីដើមបណ្តឹងរដ្ឋប្បវេណីវិញ គឺមិនទទួលបានការបង់ថ្លៃអ្វីទាំងអស់ ហើយជាញឹកញាប់ត្រូវបានតម្រូវឲ្យធ្វើការងារពីចំងាយ ដោយគ្មានប្រាក់ឧបត្ថម្ភថែមទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីថែមទាំងតវ៉ាថា ឌុច បានប្រមាថមើលងាយលើជនរងគ្រោះពីមន្ទីរស-២១ ដោយបញ្ចេញមតិមួយចំនួនទៅកាន់តុលាការ ។ ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ការពន្យាពេលក្នុងការតែងតាំងអ្នកដែលត្រូវជំនួសលោក រ៉ូប៊ែរ ពេទី សហព្រះរាជអាជ្ញាអន្តរជាតិដែលលាលែងពីតំណែងនោះ គឺធ្វើឲ្យមានអតុល្យភាពកាន់តែខ្លាំងរវាងមេធាវីការពារក្តី និងអយ្យការ ។ (កាលពីថ្ងៃទី ២៩ សីហា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាបានជ្រើសរើស លោក វីលៀម ស្មីត ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិរងក្នុងពេលបច្ចុប្បន្ន ឲ្យបំពេញតួនាទីជាសហព្រះរាជអាជ្ញាអន្តរជាតិស្តីទីរហូតដល់មានការជំនួសជាអចិន្ត្រៃយ៍មួយត្រូវបានតែងតាំងឡើង) ។

## អ្នកជំនាញបង្ហាញពីលទ្ធផលស្តីពីការវាយតម្លៃផ្នែកចិត្តសាស្ត្ររបស់ ឌុច

បន្ទាប់ពីការពន្យល់ជាសង្ខេបដោយលោក អាឡាំង វែណឺ អំពីអវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោក ហ្វ្រង់ហ្វ័រ ស៊ីរ៉ូនី ហ្គីលបូដ (Francoise Sironi-Guildbaud) អ្នកចិត្តសាស្ត្រជាតិបារាំង និង លោក ការ ស៊ុនបូណាត អ្នកចិត្តសាស្ត្រជនជាតិខ្មែរបានធ្វើសច្ចាប្រណិធាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើបទបង្ហាញរួមគ្នាស្តីអំពីសេចក្តីសង្ខេបលើការវាយតម្លៃផ្នែកចិត្តសាស្ត្ររបស់ ឌុច តាមការស្នើសុំរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ លទ្ធផលនៃការវាយតម្លៃរបស់អ្នកជំនាញទាំងពីរគឺពឹងផ្អែកលើបទសម្ភាសន៍ចំនួន ១៣ដងជាមួយ ឌុច រួមទាំងការវាយតម្លៃពីសកម្មភាពរបស់ឌុច ដូចជា ការសុំទោសពោរពេញដោយមនោសញ្ចេតនារបស់ ឌុច ចំពោះជនរងគ្រោះនៅមន្ទីរ ស-២១ និងជើងឯកជាដើម ។

អ្នកចិត្តសាស្ត្រទាំងពីររូបបានផ្តល់សក្ខីកម្មថា ឌុច មិនទទួលរងនូវការឈឺចាប់ផ្នែកសតិអារម្មណ៍ឡើយ ប៉ុន្តែ ឌុច បែរជាមកប្រើប្រាស់យន្តការការពារផ្នែកចិត្តសាស្ត្រ ជាច្រើនដែលអាចធ្វើឲ្យខ្លួនប្រព្រឹត្តអំពើដូចដែលកំពុងធ្វើនេះ ។ ជាញឹកញាប់ ឌុច តែងតែធ្វើសកម្មភាពតាមវិចារណញ្ញាណដែលថា ខ្លួនគាត់មិនមានជម្រើសអ្វីផ្សេងពីនេះ ។ ឌុច បានធ្វើឲ្យខ្លួននៅដាច់តែឯង និងគេចវេះពីស្ថានភាពជាច្រើន ដែលគាត់មិនចង់ឃើញ និងពុំពីអ្វីដែលបានកើតឡើងនៅជុំវិញក្នុងគុក ។ គួរឲ្យកត់សម្គាល់បំផុតនោះគឺថា ឌុច ប្រើប្រាស់«ការបែកចែក»ផ្នែកចិត្តសាស្ត្រ ដែលការបែងចែកនោះអាចធ្វើឲ្យគាត់អាចញែកសកម្មភាពដែលខុសគ្នា និងផ្ទុយគ្នានៅក្នុងដំណើរជីវិតរបស់ខ្លួន ។ ធ្វើបែបនេះ ឌុច អាចទទួលយកនូវទស្សនៈនៃការពិតដែលផ្ទុយគ្នា និងការពន្យល់ពីដែលខ្លួនគាត់ អាចធ្វើសកម្មភាពមួយចំនួនដូចជា ការចិញ្ចឹមបីបាច់កូន និងការធ្វើជាឪពុកដ៏ល្អម្នាក់ ស្របពេលដែលខ្លួនកំពុងតែគ្រប់គ្រងលើគុកមួយដែលក្មេងៗត្រូវបានសម្លាប់ជាប្រព័ន្ធ ។

បញ្ហាវិវាទដ៏ក្តៅគគុកមួយក្នុងអំឡុងពេលនៃសវនាការ គឺទាក់ទិននឹងភាពពិតជាក់ស្តែងនៃការសុំទោស និងវិប្បដិសារីដែល ឌុច បានលើកឡើង ។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានបដិសេធចំពោះការសុំទោសរបស់ ឌុច ដោយចោទ ឌុច ពីភាពមិនស្មោះត្រង់ ។ បើទោះបីជាមានការចោទសួរពីសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីក៏ដោយ អ្នកជំនាញទាំងពីររូប មិនបញ្ចេញមតិយោបល់ដោយផ្ទាល់លើបញ្ហានេះទេ ។ យ៉ាងណាមិញ អ្នកជំនាញទាំងពីររូបបានលើកឡើងបន្ថែមពីការអង្កេតរបស់ខ្លួនថា អាកាប្បកិរិយារបស់ ឌុច បានផ្លាស់ប្តូរជាបន្តបន្ទាប់ក្នុងអំឡុងពេលនៃការវាយតម្លៃ ។ អ្នកជំនាញទាំងពីររូបបានពន្យល់ថា នៅក្នុងបទសម្ភាសន៍ចុងក្រោយ ឌុច បានបង្ហាញពីសមត្ថភាពអាណិតអាសូរបានកាន់តែល្អជាងមុន និងពីបំណងចង់ជួយផ្តល់នូវសំណង ។ អ្នកជំនាញទាំងពីររូបបានកត់សម្គាល់ឃើញទៀតថា ដោយមិនបង្អស់យូរនឹងការចោទសួរ ឌុច បានសម្តែងពីវិប្បដិសារី និងបានប្រាប់អ្នកជំនាញទាំងពីររូបថា ខ្លួនគាត់ចង់ស្វែងរកការសុំអត់ឱនទោស ។

លោក ហ្គីលបូដ និង លោក ស៊ុនបូណាត ក៏បានលើកឡើងពីការផ្លាស់ប្តូរជំនឿសាសនារបស់ ឌុច មកជឿលើសាសនាគ្រិស្តដែលទទួលនូវរិះគន់ជាច្រើនថា គ្មានអ្វីក្រៅពីការប៉ុនប៉ងចង់លាងបាបកម្មរបស់ខ្លួនតែប៉ុណ្ណោះ ។ អ្នកជំនាញទាំងពីររូបបានពន្យល់បន្តទៀតថា គំនិតចាប់ផ្តើមជីវិតសារជាថ្មីតាមគ្រិស្តសាសនាបានផ្តល់ឲ្យ ឌុច នូវលទ្ធភាពទទួលបាននូវអត្តសញ្ញាណ និងអត្តចរិកថ្មី បើទោះបីជាមានបាបកម្មពីអតីតកាលរបស់ខ្លួនក៏ដោយ ។

ជាចុងក្រោយ លោក ហ្គីលបូដ និងលោក ស៊ុនបូណាត បានស្នើឡើងថា ឌុច អាចធ្វើឲ្យមាននីតិសម្បទាឡើងវិញបាន ។ ក្នុងគោលបំណងចង់ជំទាស់នឹងការកំណត់នេះ សហព្រះរាជអាជ្ញាបានអះអាងថា ការធ្វើឲ្យមាននីតិសម្បទាដ៏ពេញលេញឡើងវិញនឹងមិនអាចធ្វើបានទេ ពីព្រោះថា បើទោះបីជា ឌុច បានត្រៀមខ្លួន និងស្ម័គ្រចិត្តរួចជាស្រេចក៏ដោយ នៅក្នុងសង្គមដែល ឌុច នឹងត្រូវធ្វើនីតិសម្បទាឡើងវិញនោះអាចនឹងមិនទទួលយកបានឡើយ ។ លោក ស៊ុនបូណាត បានឆ្លើយតបដោយផ្តល់ជាយោបល់ថា ទោះបីជាសង្គមមិនទាន់ត្រៀមខ្លួនដើម្បីអត់ឱនទោសឲ្យ ឌុច ក៏ដោយ ឌុច នៅតែអាចរស់នៅក្នុងសង្គមនោះបាន គឺដូចមេដឹកនាំខ្មែរក្រហមដទៃទៀតដែរ ដែលធ្លាប់បានរស់នៅចាប់តាំងពីមានគោលនយោបាយផ្សះផ្សាជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាមកម្ល៉េះ ។